# បណ្ដាសារាត្រីរនោច

ប្រលោមលោកអភិនីហា អរូបិយ

ដោយ ពេជ្រ បណ្ឌិត

តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? រឿងរ៉ាវរបស់ឡានីដែលបានរៀបការចេញទៅតាមប្ដីនៅបរទេសពិតជាពិបាកនឹងជឿមែនដែរទេ? ចុះបើពេលនេះ មាស វុធ មានរឿងមួយពីបទពិសោធន៍និស្ស័យខ្មោចលង របស់គេមកចែករំលែក?

ខ្ញុំឈ្មោះវុធ ជាគ្រូបង្ហាត់ផ្នែកថតរូបនិងការរចនារូបភាព នៅសាលាឯកជនមួយ។

តាំងពីអាយុ១០ឆ្នាំ ខ្ញុំតែងតែឃើញរបស់ដែលមនុស្សម្នាមិនចង់ឃើញ។ នៅសុខៗនៅលើដំបូងផ្ទះម្ដាយខ្ញុំ ខ្ញុំឃើញមនុស្សមានស្លាបហោះចុះឡើង ហើយចួនកាលនៅកណ្ដាលយប់ ខ្ញុំឮគេច្រៀង នៅមុខថ្នាក់រៀនដែលគ្មានអ្នកណាមកសោះខ្ញុំឃើញម្ដាយពរកូន ហើយបំពេវា។ល។

អ្នកផងក្នុងភូមិថាខ្ញុំនេះជាក្មេងមានក្រយៅខ្មោចលងព្រោះជារឿយៗ ខ្ញុំអាចច្រឡំងាយក្នុងការកំណត់អត្តសញ្ញាណរវាងមនុស្សពិតប្រាកដនិងអ្នកដែលឃើញបានបន្តិចក៏រលាយបាត់ទៅវិញ។

ពួកគេតែងតែសើចខ្ញុំព្រោះអ្វីមួយចំនួនដែលខ្ញុំបានឃើញភាគច្រើននិយាយទៅគ្មានអ្នកណាមានយោបល់ទេ ព្រោះគេមិនត្រឹមតែមិនធ្លាប់បានឃើញថែមទាំងមិនជឿខ្ញុំទៀត។

ប្រការនេះ ធ្វើឱ្យខ្ញុំក្លាយជាក្មេងដែលនៅឃ្លាតឆ្ងាយពីគេម្ដងបន្តិចៗ។

ម៉ែខ្ញុំនិងលោកតា បាននាំខ្ញុំទៅរកព្រះសង្ឃនៅចុងកាត់មាត់ញកមួយឆ្ងាយពីភូមិ។

«ញោមនៅរៀនសូត្រធម៌ជាមួយអាត្មាឱ្យបានមួយវស្សាទៅ!»

ដោយសារខ្ញុំជាប់រៀន ខ្ញុំនៅនឹងលោកបានតែពីរអាទិត្យ ម៉ែក៏មកយកទៅផ្ទះវិញ។

ទោះបីយ៉ាងណាខ្ញុំបានទន្ទេញចេះធម៌មួយចំនួន ដូចជា ពុទ្ធំ សរណំ គច្ឆាមិ. ធម្មំ សរណំ គច្ឆាមិ. សង្ឃំ សរណំ គច្ឆាមិ.ទុតិយម្បិ ពុទ្ធំ សរណំ. ទុតិយម្បិ ធម្មំ សរណំ គិច្ឆាមិ. ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ.តតិយម្បិ ពុទ្ធំ សរណំ គិច្ឆាមិ. តតិយម្បិ ធម្មំ សរណំ គិច្ឆាមិ. តតិយម្បិ សង្ឃំ សរណំ គិច្ឆាមិ ហើយខ្ញុំចេះតែគិតថា មានធម៌នេះជាប់អណ្ដាត ឬសូម្បីតែគិតទន្ទេញក្នុងក្បាល ក៏អាចនឹងនរចិត្តកក់ក្ដៅច្រើនជាងមុនពេលខ្លួនទទេទើបក្រោយមកអ្វីៗគ្រាន់បើឡើងវិញ ខ្ញុំដេកលក់ស្កប់ជាងមុន ហើយមិនសូវឃើញនូវអ្វីដែលអ្នកផងមិនធ្លាប់ឃើញនោះទៀតទេ។

ចួនកាល ខ្ញុំបានឃើញក្មេងតូចៗត្រងោលជាច្រើនមិនសមជាកូនអ្នកស្រុក ពួកវារត់ប្រញាយតាមផ្លូវ ខ្ញុំគិតថាជា ម្រិញគង្វាល តែខ្ញុំមិនមានអារម្មណ៍ខ្លាចអ្វីសោះ ដោយគ្រាន់តែសូត្រធម៌ដដែល ក៏អាចបញ្ឈប់លែងឃើញពួកគេ។

អ៊ីចឹងហើយ តមក ខ្ញុំមានគំនិតការពារបរិវេណផ្ទះរបស់ខ្ញុំ ដោយការឆ្លាក់ធម៌ដ៏សំខាន់នេះ នៅជាប់លើជញ្ជាំងឈើ។ ក្រោយៗមក ខ្ញុំនិងគ្រួសារបានរស់សុខសាន្តលែងឃើញវត្ថុមិនពិតអស់នោះទៀត រហូតដល់ខ្ញុំបាន១៨ឆ្នាំ។

ដូចជាមិនដែលមានបញ្ហាណាមួយជាដុំកំភួនកើតមានឡើងបាននៅក្នុងផ្ទះរបស់ខ្ញុំ រហូតដល់ខ្ញុំលែងនៅផ្ទះនោះទៀត។

ជាការប្រសើរណាស់ព្រោះខ្ញុំបានជាប់បួកមកភ្នំពេញបន្តចូលមហាវិទ្យាល័យ។

ខ្ញុំបានទទួលឱ្យស្នាក់នៅអន្តេវាសិកដ្ឋាន សម្រាប់និស្សិតមកពីខេត្តហើយប្រុសនៅអាគារផ្សេង ស្រីនៅអាគារផ្សេង។

នៅយប់ដំបូង ខ្ញុំសឹងតែបានភ្លេចពីក្រយ៉ៅខ្មោចលងរបស់ខ្លួន។

រហូតដល់ម៉ោង១០យប់ដែលខ្ញុំចេញពីជប់លៀងស្វាគមន៍និស្សិតថ្មីៗ ហើយដើរកាត់សួនច្បារ ដ៏ធំក្នុង សាកលវិទ្យាល័យ វិលមកអគារសម្រាក។

ខ្ញុំមកពីជនបទ ហើយមានទម្លាប់ឆាប់ងងុយឆាប់ចូលគេ ម្ល៉ោះហើយខ្ញុំសុំចេញមកមុនគេឯង អ្នកឯទៀតៗគេនៅបន្តសប្បាយចិត្តជាមួយការរាំច្រៀងសិន។

ភ្លេងឮកាន់តែឆ្ងាយទៅៗ  ខ្ញុំវិញស្ងាបផង រោយជើងផងព្រោះឈរយូរពេក។

ដើម្បីទៅដល់ខាងអាគារសម្រាកប្រុសៗរហ័ស ខ្ញុំត្រូវតែរើសយកការដើរអែបកៀនៗអាគារនានាជាជាងតាមផ្លូវ ។ទីនេះមិនសូវភ្លឺច្បាស់ព្រោះឆ្ងាយពីចង្កៀងគោមគួរសម ដូច្នេះខ្ញុំត្រូវបង្កើនល្បឿន។

ស្រាប់តែពេលភ្លាមៗនោះ ខ្ញុំហាក់ ស្ដាប់ឮសំឡេងចម្លែកមួយចំនួន។

ម្ដងៗដូចជាសូរស្នូតបុណ្យសព ចួនដូចមនុស្សសើចជាក្រុម ចួនមនុស្សស្រីនិយាយទូរស័ព្ទ។

ដំបូងខ្ញុំមិនរវល់ តែបន្តិចមក ខ្ញុំនឹកចម្លែកចិត្ត។

ហេតុអ្វីអកកេះខ្លាំងយ៉ាងនេះ នៅតែបាត់ល្វើយៗ បែរជាឮសំឡេងផ្សេង?

អាគារអស់នេះ ស្ងាត់ជ្រងំ មានមនុស្សពីណាមក?

ខ្ញុំរៀបនឹងហាមាត់សួត្រធម៌ ស្រាប់តែកន្ទុយភ្នែកក្រឡេកទៅឃើញ ក្រោមអំពូលអគ្គីសនីលម្អសួនមួយយ៉ាងចាស់ស្រអាប់ ខ្ញុំហាក់ឃើញវត្ថុមានជីវិត។

ពិតណាស់ ខ្ញុំបានឃើញក្មេងស្រីជំទង់ម្នាក់ ទំនងជាក្មេងជាងខ្ញុំ ច្រើនដែរ។

នាងមើលទៅស្លៀកពាក់ជានិស្សិត នឹងមានសក់វែងក្រងជាជួរ។

នាងកំពុងនិយាយទូរស័ព្ទមិនរវល់សូម្បីតែខ្ញុំដើរកាត់។

មេឃគ្មានព្រះខែតែអំពូលអគ្គីសនីជះយ៉ាងវែងមកចំពីលើពួកយើង។

ចិត្តខ្ញុំលែងភ័យខ្លាចអ្វី ព្រោះយល់ថា គេជាស្រី គេមិនខ្លាចផង ខ្ញុំប្រុសធំប៉ុណ្ណឹងដែរ ទៅខ្លាចអី?

ខ្ញុំដើរយ៉ាងរំភើយ ឆ្ពោះទៅមុខ ហើយសម្លឹងស្រមោលខ្លួនឯងដែលរេថយក្រោយលើដីសាលាណែននឹងរៀបស្មើរក្រោយភ្លៀងសើមកាលពីព្រឹក។

ហេតុអ្វីមនុស្សមានពីរនាក់តែស្រមោលមានតែមួយ?

ខ្ញុំព្រឺក្បាល ហើយឈានទៅមុខលែងបាន។

ការបែរក្រោយរកមើលនារីជារឿងដែលខ្ញុំគ្មានចេតនាធ្វើដាច់ខាត តែខ្ញុំបានបែរទៅហើយ។

អូយ! អត់មានអ្នកណាផង! សិស្សនារីឯណាមកឈរនិយាយទូរស័ព្ទនៅត្រង់នេះ?

មានតែម្លប់ឈើត្រៃឈៃនៅទីនោះ ហើយនឹងខ្យល់បោកបង្កសំឡេងប្រាកៗ ។

ខ្ញុំដាក់មេផាយយ៉ាងលឿន។

ខ្ញុំគួរតែមិនមែនឆ្ពោះទៅអាគារទេ គួរតែបកទៅកន្លែងជប់លៀងវិញព្រោះមិនទាន់មានអ្នកណាបកមកដេកនៅឡើយ តែក្នុងកាលៈទេសៈនេះ ខ្ញុំឯណាអាចគ្រប់គ្រងគោលដៅបាន។

ទីបំផុតអាគារដេកលេចឡើងចំពីមុខខ្ញុំចម្ងាយប្រមាណជា៥០ម។

ប៉ុន្តែមុនទៅដល់ទីនោះ ខ្ញុំឃើញចំណតឡានម៉ូតូមួយនៅកៀកជាង និងមានប្រកសំយ៉ាបស័ង្កសីព្រមទាំងអំពូលអគ្គិសនីផង។

ខ្ញុំមិនបានគិតអ្វីច្រើនព្រោះជឿថានិងមានមនុស្សនៅទីនោះយាមជំនិះមិនខាន ដូច្នេះខ្ញុំបែរទៅទីនោះវិញ។

តាមពិតចរិតភ័យខ្លាចខ្មោចរបស់ខ្ញុំបានកម្រើកមកវិញទៅហើយ បេះដូងរបស់ខ្ញុំកំពុងមានសន្ទុះ

ខ្លាំងក្លា គ្រាន់តែខ្ញុំខំទប់ហើយរក្សាការដើរធម្មតាវិញ លែងរត់កុំឱ្យខ្មាសគេ។

ខ្ញុំចង់ស្រែកសួរពីចម្ងាយថា តើមានអ្នកណានៅដែរទេ? ប៉ុន្តែបើសួរដូច្នេះនាំតែគេដឹងថាខ្ញុំនេះត្រូវខ្មោចលង?

ខ្ញុំដើរមកដល់ក្រោមសំយ៉ាបហើយឈប់ទាំងហត់គឃុស។

មិនទាន់អីផង សត្វឆ្កែមួយរត់ឆ្វាចពីក្រោយខ្នងខ្ញុំ។

ខ្ញុំងាកទៅដោយអរថា មានឆ្កែច្បាស់ជាមានមនុស្សនៅក្បែរៗនេះ?

តែដោយឆ្កែមានភ្នែកហាក់ថ្លាមុតព្រមទាំងសម្លឹងមើលមកខ្ញុំយ៉ាងចម្លែក ចិត្តខ្ញុំរំជួលសារជាថ្មី។

ខ្ញុំបោះបង់ចោលគំនិតស្វែងរកម្ចាស់សំយ៉ាបនេះហើយដើរធ្វើហីមួយៗទៅរកអាគារស្នាក់វិញ ស្រាប់តែ វាលូមករ៉ាវតាមពីក្រោយខ្នង។

ចិត្តភ័យខ្លាចរបស់ខ្ញុំបានកម្រើកភ្ញាក់ឡើងមកវិញ។ យ៉ាងហោចណាស់ខ្ញុំគិតថា ឆ្កែលូ ជាប្រផ្នូលមិនល្អទេពិសេសកណ្ដាលយប់ស្ងាត់ ហេតុអ្វីវាសម្លឹងខ្ញុំហើយលូ?

ខ្ញុំបានដើរត្រដាបត្រដួស ហើយចុងក្រោយបិទភ្នែកសូត្រធម៌ទាំងដើរតែម្ដង។

ដោយសារតែការបិទភ្នែកនោះហើយ បានជាខ្ញុំដើរបុកមនុស្ស

«អូយ!»

«ខ្ញុំសុំទោស!»

ខ្ញុំបើកភ្នែកឡើងឃើញប៉ូវ៉ាកំពុងយួរទឹកក្រូចពីរយួរនៅនឹងដៃហើយរត់ចេញមកពីអាគារ។

គឺខ្ញុំនិយាយសុំទោសដែលដើរបុកគេមុន។

«វុធឯងចូលគេងហើយ?»

«ខ្ញុំងងុយណាស់!»

«ម៉ែ! ទៅវិញសិនហ្អី?»គេបបួលធ្វើឱ្យចិត្តខ្ញុំរារែក។

ខ្ញុំមិនចង់បកទៅវិញជាមួយប៉ូវ៉ាទេ តែចិត្តរបស់ខ្ញុំក៏មិនចង់គេងតែឯងស្ងាត់ជ្រងំដែរ។

«មានអ្នកណានៅកន្លែងគេងអត់?»

«អត់ដឹងទេតែប្រហែលជាមាន!»

គេឆ្លើយហើយរត់រឹងទៅកន្លែងពិធី ដូចជាប្រញាប់ទៅសប្បាយណាស់បន្សល់ខ្ញុំនៅម្នាក់ឯងងាកមកសម្លឹងអាគារស្នាក់នៅ។

ពីជាន់ទីមួយ ខ្ញុំដូចជាឃើញមានមនុស្សពីរនាក់កំពុងស្លៀកខោខ្លីគ្មានអាវឈរនិយាយគ្នា។

ចិត្តខ្ញុំនឹងនរបន្តិច ដើរចូលទៅរកបន្ទប់។ វាជាបន្ទប់ចុងក្រោយគេនៅជួរខាងស្តាំនៃជាន់ផ្ទាល់ដី។

បរិយាកាសស្ងាត់ណាស់ បើចូលក្នុងបន្ទប់ភ្លាមៗដូចជាសុវត្ថិភាពជាង។

ខ្ញុំរាវរកសោរហើយលើកមកមួលក្នុងរន្ធ មុនពេលបើកគន្លឹះទ្វារបាន ខ្ញុំឮសំឡេងរោទិ៍ទូរស័ព្ទនិងស្នូរជើងមនុស្សដើរចុះឡើងនៅបន្ទប់ទល់មុខខ្ញុំ។

«អូខេហើយ មានគេនៅទីនេះដែរ!»

ខ្ញុំចូលដល់បន្ទប់កាលណា បិទទ្វារវិញគ្រឹបហើយបើកភ្លើងចិញ្ចាច។

សូម្បីតែបន្ទប់ទឹក ក៏ខ្ញុំបើកភ្លើងដែរ។ បន្ទប់នេះមានគ្រែ៤ ប៉ុន្តែគ្មាននរណាម្នាក់នៅទេ គេនៅច្រៀងរាំនៅឡើយ។

វាំងននបង្អួចរបស់ខ្ញុំបិទស្រាប់ហើយតែខ្ញុំនៅតែលូកដៃទៅទាញផ្ចិតទៀតមិនចង់ឱ្យមានសល់សូម្បីតែប្រហោះអ្វីបន្តិចណា។ គ្រែខ្ញុំនេះបែរទៅចំនឹងបង្អួចមួយដែរ តែមិនកៀកពេកទេ ។ ទ្វារបន្ទប់នៅខាងឆ្វេងដៃខ្ញុំបង្អើយ ពោលគឺខ្ញុំងើបភ្លាមអាចឈានដល់ទ្វារភ្លែត។

ខ្ញុំគិតថាដំបូលនេះទាបបន្តិច វាគួរតែក្តៅហប់ដែលមកបិទបង្អួចជិតយ៉ាងនេះតែបែរជាត្រជាក់ខ្លាំងទៅៗទៅវិញ?

ត្របកភ្នែកខ្ញុំទន់ធ្លាក់សន្សើម ធ្វើឱ្យខ្ញុំត្រៀមខ្លួនជាស្រេចក្នុងការដេកលក់ឱ្យស្កប់ដូចពាក្យចាស់លោកថា ដេកលក់បាត់ខ្លាច។

ខ្ញុំទាញភួយមកគ្របដល់ចុងជើងហើយសូត្រធម៌ជានិច្ចក្នុងចិត្ត រហូតដល់អារម្មណ៍ងងុយគេងគ្របដណ្តប់បានទាំងស្រុងមកលើអារម្មណ៍ភ័យខ្លាច។

នៅក្នុងការចាប់ផ្តើមសុបិនខ្ញុំនៅតែចាំបានថា ខ្ញុំដេកនៅលើគ្រែហើយ  បន្ទប់ទាំងមូលបានបើកភ្លើងសូម្បីតែបន្ទប់ទឹក។ ចុះហេតុអ្វីពេលនេះ ខ្ញុំបើកភ្នែកមវិញបន្ទប់ទាំងមូល ហាក់ក្លាយទៅជាពណ៌ខ្មៅងងឹត?

ខ្ញុំខំច្រតដៃក្រោកដើម្បីមើលម៉ោង ចុះហេតុអ្វីមានអារម្មណ៍ថា ជង្គង់របស់ខ្ញុំទន់ លើកជើងមិន

បានសោះ?

ខ្ញុំខំសម្លឹងផ្ចិតទិដ្ឋភាពពិតាន លើក្បាល ហើយចាប់ផ្ដើមភ័យព្រោះទទួលអារម្មណ៍ថាខ្ញុំដកដង្ហើមមិនរួច គឺកំពុងតឹងច្រមុះណែនតែម្ដង។

ខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីដេកភ័យខ្លាចឬស្រែករកជំនួយនោះឡើយ ពីព្រោះអ្វីពណ៌ខ្មៅយ៉ាងធំនិងធ្ងន់បានធ្លាក់មកពីលើពិតានហើយសង្កត់ខ្ញុំដែលកំពុងតែដង្ហក់ស្រាប់។

ខ្ញុំខំប្រយុទ្ធព្រោះបើបន្លាយពេលខ្ញុំដាច់ដង្ហើមហើយ។

កាន់តែរុញចេញ វាកាន់តែធ្ងន់ឡើងៗ?

ខ្ញុំបែកញើសតឹងហប់ហើយលែងអាចបម្រះក៏ទន់ខ្លួនតាមយថាកម្ម តែចិត្តប្រឹងសូត្រធម៌។

ខ្ញុំសូត្រហើយសូត្រទៀត រហូតដល់មានអារម្មណ៍ថាទ្វាររបើក ខ្វាកនាំមកនូវអុកស៊ីសែន។

ពេលនោះហើយដែលស្រមោលខ្មៅរលាយបាត់សូន្យ នាំមកនូវមិត្តរួមបន្ទប់ខ្ញុំពីរបីនាក់ ចូលមកដល់។

ពួកគេញញឹមញញែម ព្រោះទើបតែមកពីជប់លៀង។

«គេងបើកភ្លើង?»

ម្នាក់ឈ្មោះឡេង សួរខ្ញុំ។

ខ្ញុំមិនដឹងគេចង់ឌឺឬអ្វី តែខ្ញុំឆ្លើយធ្វើដូចអត់មានរឿងអ្វីកើតឡើង៖

«មិញមើលសៀវភៅ មើលលេងៗ ក៏លក់មួយភាំង!»

«សូមទោសដែលខ្ញុំបើកទ្វារមកឮៗពេកភ្ញាក់រុំធឯង»

តាមពិតខ្ញុំត្រូវអរគុណគេទៅវិញ បើកុំតែអ៊ីចឹងតើខ្មោចនោះឈប់សង្កត់ខ្ញុំទេ?

ទោះយ៉ាងណា ខ្ញុំមិនបាននិយាយអ្វីប្រាប់ពួកគេនោះទេព្រោះខ្លាចគេសើចកំប្លុកកំប្លែងមើលស្រាលយើង។

ស្អែកឡើង.....

ខ្ញុំភ្ញាក់ដឹងខ្លួនពេលស្រាងៗ។ បង្អួចបើកចំហរហើយមិត្តរួមបន្ទប់នៅបន្តគេងដដែល។

ការហាត់ប្រាណដោយរត់ត្រឹកៗជាទម្លាប់ខ្ញុំតាំងពីនៅខេត្ត អ៊ីចឹងហើយ ខ្ញុំចាប់ផ្ដើមការរត់ដំបូង

នៅទីនេះសាកលោមើលដោយក្រោយឃើតៗកុំឱ្យរំខានអ្នកដទៃ។

បន្ទប់ពីមុខខ្ញុំនេះចាក់សោរពីក្រៅ មានន័យថាម្ចាស់គេបានក្រោកព្រឹកជាងខ្ញុំទៅទៀត។

ខ្ញុំចាប់ទិសដៅទៅរកសួនធំមួយដែលមើលទៅត្រជាក់សល់ពីសន្សើម។

មាននិស្សិតពីរបីនាក់ជិះកង់កាត់ពីរមុខខ្ញុំ ធ្វើឱ្យខ្ញុំកាន់តែមានអារម្មណ៍ស្រស់ថ្លាថែមឡើង។

ខ្ញុំរត់ចុះឡើងដោយសប្បាយចិត្តបំភ្លេចរឿងកាលពីយប់ ហើយពេលហត់ខ្ញុំឈប់អង្គុយលើបង់ថ្ម។

សាលប្រជុំដ៏ធំមួយ លេចឡើងនៅនឹងមុខខ្ញុំ។

នេះជាអាគារមានបែបផែនដូចជាសាងឡើងក្នុងជំនាន់បារាំង ដែលមានអាយុចំណាស់ជាងសំណង់ផ្សេងៗនៅក្នុងមហាវិទ្យាល័យរបស់យើង។

មើលទៅវាជាកន្លែងមួយស្ងាត់ណាស់ព្រោះទីតាំងស្ថិតនៅខាងចុងបំផុតនៃសួន ។ខ្ញុំក្រោកដើរទៅ ហើយគិតពីរូបភាពមួយចំនួនដែលអាចនឹងដាក់ប្រលង យករង្វាន់បានទាក់ទងនឹងសំណង់នេះ។

ផ្លូវលំតូចៗជុំវិញសាលនេះពេញដោយកាកសំណល់ហាក់បីដូចជាមិនសូវមានអ្នកណាខ្វល់នឹងថែទាំ វាសោះឡើយ។

នៅលើជញ្ជាំងទីមួយដែលខ្ញុំបានទៅដល់មុនគេ  ខ្ញុំឃើញមានស្នាមពាក្យពេចន៍ស្នេហាមួយចំនួនសរសេរក្នុងលក្ខណៈតួអក្សរខុសៗគ្នា ទំនងជាយុវវ័យពីមុនៗគេតែងតែ និយមនាំគ្នារើសយកទីកន្លែងនេះមកសសេរពាក្យពេចន៍មនោសញ្ចេតនាតាម គ្នាទេដឹង។

ខ្ញុំឈរមើលឃ្លានីមួយៗយ៉ាងជក់ចិត្តព្រោះភាសាខ្លះផ្អែមរហូតដល់ឱ្យយើងព្រឺសម្បុរតែភាសាខ្លះកម្សត់អាណោចអាធ័ម។

រហូតដល់ទូរស័ព្ទខ្ញុំរោទ៍ទើបខ្ញុំភ្ញាក់មកវិញហើយដឹងថាជិតដល់ម៉ោងចូលរៀនត្រូវស្រូតទៅរៀបចំខ្លួន។

ចេញមកដល់ក្រៅខ្ញុំឃើញបូរ៉ាកាន់ដបទឹកដើរសំដៅមក។ គេញញឹមរាក់ទាក់តាមទម្លាប់របស់គេ។

«មកពីណាវុធ?»

គេកៀកកខ្ញុំបណ្តើរទៅបន្ទប់វិញ ឆ្លៀតពេលនេះខ្ញុំនិយាយប្រាប់គេខ្សឹបៗដោយសារតែចិត្តនៅមិន

ទាន់រសាយចេញពីជញ្ជាំងដែលពេញដោយភាសាស្នេហាយុវវ័យនោះ។

«នៅអាគារចាស់នោះសុទ្ធតែសរសេររឿងស្នេហារញ៉េរញ៉ៃ! កោតតែនាយកសាលានេះអត់ថាអីវ៉ី?»

បូរ៉ាចេញប្រតិកម្មហាក់ដូចជាមិនដែលបានឃើញជញ្ជាំងនោះទេ គេចំហមាត់ធ្លុងដូចភ្ញាក់ផ្អើល៖

«នៅឯណា? ចង់ថត Postលេងអ្នា!»

ខ្ញុំឃាត់វិញ៖

«ដល់ម៉ោងហើយទៅរៀនសិន!»

បូរ៉ាបង្ខំចិត្តទៅតាមខ្ញុំវិញព្រោះពិតជាកៀកម៉ោងមែន។

ល្ងាចឡើងម៉ោងប្រហែល ៧កន្លះយប់ ខ្ញុំមកពីញ៉ាំបាយតែម្នាក់ឯង។

ទុកម៉ូតូរួចខ្ញុំដើរទៅរកកន្លែងជុំគ្នាធ្វើAssignment ដែលកំណត់នៅក្នុងអាគារសិក្សា។

ផ្លូវក្នុងមហាវិទ្យាល័យងងឹតខ្លះភ្លឺខ្លះមេឃរលឹមប្រុយៗ យប់នេះទំនងត្រជាក់ដេកដណ្តប់ភួយស្រួលមិនខាន។

ខ្ញុំខំដើរឱ្យរហ័ស មិនរវល់រំខាននិងអ្វីៗជុំវិញខ្លួនទេ តែសំឡេងខ្សឹបខ្សៀវសើចសប្បាយរវាងប្រុសនិងស្រីបានលាន់ឮមកល្វើយៗតាមព្រះវាយោ។

ខ្ញុំបន្ថយល្បឿនហើយសំឡេងសើចលាន់មករឹតតែច្បាស់។

អាគារដែលមានជញ្ជាំងពេញដោយពាក្យពេចន៍ស្នេហាបែរជាមើលឃើញច្បាស់នៅចំពោះមុខខ្ញុំ តើសំឡេងប្រុនិងស្រីពិតជាលាន់ចេញមកពីទីនោះហ្មែន?

ខ្ញុំតាំងចិត្តថាមិនរវល់នឹងភាពទាក់ទាញយ៉ាងអាថ៌កំបាំងរបស់ទីនោះទេ ប៉ុន្តែមិនដឹងយ៉ាងម៉េចជើងខ្ញុំបានបំបែរទិសដៅដើរលុកលុយកាត់ ស្មៅនិងបន្លារបស់រុក្ខជាតិមួយចំនួនឆ្ពោះទៅរកទីនោះទៅវិញ?

មកដល់ប្រមាណ បីម៉ែត្រពីច្រកទ្វារចូលទៅក្នុងខ្ញុំមានអារម្មណ៍ថាពន្លឺចង្កៀងប្រេងកាតជះពន្លឺចេញមកពីបរិវេណខាងក្នុងដែលខ្ញុំមិនធ្លាប់ចូលដល់។

....ព្រឺសម្បុរ.....

សញ្ញាណនៃការប្រឈមនិងខ្មោចលង បានវិលមកសណ្ឋិតក្នុងចិត្តខ្ញុំ ហើយខ្ញុំចង់បកក្រោយណាស់ ប៉ុន្តែទោះបីជាយ៉ាងណា ខ្ញុំនៅតែចង់ដឹង ថាអ្នកណា នៅខាងក្នុង គេកំពុងធ្វើអ្វី លួចលាក់លេងល្បែងស្នេហា?

ការចង់ដឹងនៅតែឈ្នះចិត្តភ័យខ្លាច ដូច្នេះចុងក្រោយ ខ្ញុំបានសម្រេចចិត្តច្បាស់លាស់ក្នុងការឈានចូលទៅក្បែរបង្អួច។

បង្អួចដែលមានអាយុកាលដ៏ជរា មើលទៅហាក់ដូចជា មិនមានសេសសល់រចាំងកញ្ចក់ណាមួយផ្ទាំងទេ បានជាធ្វើឱ្យខ្ញុំនេះមានភាពងាយស្រួលក្នុងការស្តាប់អ្វីៗឮនឹងត្រចៀក។

ផ្ទៃខាងក្នុងអាគារងងឹតស្លុប ចំណែកពន្លឺចង្កៀងមុននេះម៉េចរកប្រភពលែងឃើញ?

ខ្ញុំប្រាប់ខ្លួនឯង៖

«ខ្មោចលងអ្ហែងទៀតហើយអាវុធ!»

តែទោះយ៉ាងណាខ្ញុំនៅតែឮសូរដង្ហើមមនុស្សប្រុសស្រីប្រលែងគ្នា។

ពិលទូរស័ព្ទដៃបានបញ្ចេញពន្លឺតាមសន្ទុះចិត្តស្វែងរកការពិតរបស់ខ្ញុំ!ម្តងៗខ្ញុំចង់តែស្រែកសួររកម្ចាស់សំឡេង តែចិត្តមួយខំទប់មកវិញ ព្រោះស្តាប់មិនច្រឡំទេថា ច្បាស់ណាស់នេះជាសំឡេងមនុស្ស កំពុងវង្វេងក្នុងស្នេហាគិតថាមានតែគេពីរនាក់។

កំពុងផ្ចង់រេពិលរកមើលយ៉ាងតឹងចិត្តស្រាប់តែរំពេចនោះដង្ហើមមនុស្សលាន់ស្រាវមកក្បែរត្រចៀកខ្ញុំ។ ទទួលអារម្មណ៍ថានរណាម្នាក់កំពុងមកឈរក្បែរហើយមើលមកខ្ញុំពីក្រោយខ្នង។

ខ្ញុំស្រែកវ៉ាស លើកដៃវាសខ្ញុំច្រានវាចេញរបូតទូរស័ព្ទខ្ពាកទៅលើស្មៅ។

ក្នុងពេលភ័យតក្កមា ក៏មានអារម្មណ៍បន្តថា ដូចជាមនុស្សម្នាក់បានវាយមួយដៃមកលើកញ្ចឹងកខ្ញុំធ្វើឱ្យឈឺស្ពឹកមុនពេលខ្ញុំអាច ងាកក្បាល ដើម្បីទៅពិនិត្យមើលនៅពីក្រោយ។

ខ្ញុំដួលស្រុប ហើយចាប់ផ្តើមលែងអាចដកដង្ហើមបាន។

សតិខ្ញុំប្រាប់ថាខ្ញុំចង់ស្ទាវាក្រោកឡើងឱ្យបានកាន់តែឆាប់កាន់តែល្អ គេចចេញពីកន្លែងនេះ ហើយមាត់ខ្ញុំប្រឹងស្រែក៖

«ចោរ!»

តែស្រែកមិនឮសោះ ឮតែក្នុងចិត្ត ក្នុងខួរក្បាលខ្លួនឯង ដង្ហើមដកលែងបាន ថប់ពេញទំហឹងទឹក

ភ្នែករបស់ខ្ញុំបានចាប់ផ្ដើមធ្លាក់ស្រោចហើយដឹងខ្លួនឯងថាឈឺក្បាលខ្មៅកៗ។

ខ្ញុំខំស្រែកថែមម្ដងទៀត តែស្រែកអស់មួយទំហឹងកូនប្រុស៖

«ជួយ»

សម្រែកដ៏ខ្លីមួយនេះបានរត់ចេញមកតាមបំពង់ករបស់ខ្ញុំយ៉ាងតឹងតែងទម្រាំខ្ញុំបើកភ្នែករួចហើយកន្ត្រាក់ដៃ។

ឡេង និងមិត្តពីរនាក់ទៀតសម្លឹងមកខ្ញុំពីចុងជើង។

ដែលនាងត្រូវបានគេឈរនៅជណ្ដើរកំពូល។ ខ្ញុំទើបនឹងដឹងថា នេះជាការយល់សប្ដិ។

ខ្ញុំខំដកសម្រួលដង្ហើមពោលថាខ្ញុំមិនអីទេតែគ្រប់គ្នានៅតែបារម្ភ។

«ទៅលេងធ្វើassignment អត់? បើអត់ស្រួលខ្លួនដេកទៅ!»

ខ្ញុំងក់ក្បាលឱ្យពួកគេចាកចេញទៅព្រោះត្រូវការសំងំដោះស្រាយឱ្យខ្លួនឯងបន្តិច។

«ចុះយល់សប្ដិអីក៏ស្ដែងម្ល៉េះ?»

ដេកសៅហ្មងចំពោះអារម្មណ៍មិនល្អនេះបានបន្តិច ខ្ញុំឮស្នូរគោះទ្វារ។

មិនសមថាពួកគេភ្លេចយកសោរទៅនោះទេ។

ខ្ញុំក្រោកឃើតៗទាំងដៃជើងនៅល្វើយព្រោះដេកយល់សប្ដិភ័យខ្សោះ។

ពេលមួលសោរបើកទ្វារគ្មានឃើញអ្នកណាទាំងអស់ប៉ុន្តែពេលមើលទៅបន្ទប់ខាងមុខខ្ញុំទ្វារគេទើបតែបិទទៅវិញគ្រឹប? អូយ?

អ្នកណាម្នាក់មានចេតនាបន្លាចខ្ញុំទេដឹង?

និស្សិតនៅខាងមុខនេះជាអ្នកណា? ម៉េចក៏គេមិនដែលចេញមករាក់ទាក់ក្រុមយើងសោះ? ខ្ញុំវិលមកដេក ហើយរាវបើកទូរស័ព្ទលេង Wi-Fi បន្លប់។

អ្វីមួយចាប់ផ្ដើមរំខាន។

គឺសំឡេងដែលមិនបានចេញមកពីទូរសព្ទ័ទេតែហាក់ដូចជាកំពុងកើតឡើងនៅក្រៅបន្ទប់។

អ្នកណាទេដើរចុះឡើងត្រឡប់ត្រឡិនជុំវិញចុះនៅក្នុងអាគារនេះក្បែរៗបន្ទប់ខ្ញុំ។

សូរស្បែកជើងផ្ទាត់មិនចេះថ្មម ស្ដាប់កាន់តែយូរទៅកាន់តែសង្កៀរត្រចៀក។ ត្រចៀកតែខ្ញុំទើប

មកស្នាក់ មិនចង់មានរឿងបានជាខំអត់មិនចេញទៅសួរនាំ។

ខ្ញុំឃ្លុំភួយរហូតលង់លក់។

អ្វីៗកន្លងទៅបានធម្មតាប្រមាណពីរអាទិត្យព្រោះតែពួកយើងរវល់ត្រៀមប្រលងដល់មានកម្មវិធីរៀននិងពិភាក្សារួមគ្នាដល់យប់ៗគ្មានពេលជជែកឬគិតពីរឿងចម្លែកៗនៅទីនេះទេ។

ប៉ុន្តែយប់ទី១៥ជាយប់ចុងក្រោយនៃខែរនោច.....

នៅពេលដែលខ្ញុំនៅតែឯទៀត ខ្ញុំអង្គុយសរសេរAssignmentលើគ្រែបែរខ្នងទៅបង្អួច។ ស្នូរគោះទ្វារលាន់មក ច្រើនដងដែរ ទម្រាំខ្ញុំចាប់អារម្មណ៍ហើយក្រោកភ្លែតទៅបើកទ្វារដោយគ្មានខ្វល់ខ្វាយពីអ្វីទាំងអស់។

ស្ងាត់ច្រៀប ....គ្មានអ្នកណាម្នាក់ទេ!

ប្រការនេះ រម្លឹកខ្ញុំដល់ស្ថានភាពដូចគ្នាកាលពី១៤ថ្ងៃមុន។

ខ្ញុំស្ទើរឈប់ដកដង្ហើមហើយចោលភ្នែកទៅរកទ្វារបន្ទប់ទល់មុខ។

ច្បាស់នឹងភ្នែកស្រស់ ខ្ញុំពិតជាភ្ញាក់ផ្អើលជាខ្លាំងក្នុងការមើលឃើញជាយសំពត់មនុស្សស្រីដែលដកយ៉ាងរហ័សលាក់ទៅខាងក្នុង មុនពេលទ្វាររំកិលបិទគ្រឹប។

«គេមកគោះទ្វារខ្ញុំធ្វើអី? ហើយហេតុអីទីនេះមានមនុស្សស្រីស្នាក់នៅ?»

សំនួរផុសមកតែយឺតជាងដៃខ្ញុំដែលគោះទ្វារបន្ទប់នោះ។

ខ្ញុំគោះរកម្ចាស់បន្ទប់ដើម្បីចេញមកសួរនាំពីរឿងចម្លែកអស់នេះ ប៉ុន្តែគោះយ៉ាងណាក៏គ្មានអ្នកចេញមកសោះ។

ខ្ញុំមិនចង់អត់ទ្រាំលាក់ចិត្តខឹងក៏និយាយបង្អើរៈ

«ពូកែលេងម៉េះ? មុខម៉េចហ្នឹង!?»

ស្ងាត់ច្រៀបគ្មានឮសូម្បីតែរុយហើរមួយ។ ប្រការនេះកាន់តែដុតខ្ញុំឱ្យខឹង។

ខ្ញុំរអ៊ូបន្តៈ

«តែម្តងទៀតដឹងហើយ!»

ថាចប់ខ្ញុំបែរក្រោយបកមកបន្ទប់ស្រាប់តែឮសូរទ្វាររបើកងឺតពីក្រោយខ្នងខ្ញុំ។

សូរសព្ទនោះដូចជាឃើតពេកហើយ អន្លាយពេកហើយ ដូចជាវ៉ារបើកគ្មានអ្នកណាបើក ហើយដូចលាយសំឡេងតម្បូញផង?

ខ្ញុំបើកភ្នែកធំៗ បែរក្រោយខ្វាច់។

នៅចម្ងាយមិនដល់បីម៉ែត្រឆ្ងាយពីគ្នា ខ្ញុំសម្លឹងទៅបន្ទប់ចម្លែកនោះហើយមើលមិនឃើញអ្វីទាំងអស់ព្រោះទីនោះងងឹត។

ទោះបីយ៉ាងណា ខ្ញុំបានឮសូរមនុស្សស្រីណាម្នាក់ ថ្ងូររហឹសហាក់ឈឺចាប់។

«អ្នកណាកើតអីនៅក្នុងនោះ?»

ខ្ញុំស្រែកសួរទាំងចិត្តពិបាក។ ចិត្តមួយបារម្ភថាពួកគេកំពុងរួមដៃលេងខ្ញុំ ចិត្តមួយគិតបារម្ភថាមានអ្នកណាកើតអីក្នុងនោះ ព្រោះថ្ងូរឮជាសំឡេងមនុស្សស្រី។

ខ្ញុំដើរទៅកាន់ទ្វារឃើតៗ។

នៅក្នុងបន្ទប់ងងឹតតែមិនស្លុបទេ។

ខ្ញុំហាក់ឃើញអ្នកណាម្នាក់ដេកដួលនៅលើឥដ្ឋហើយមានភិនភាគមនុស្សស្រី។

«តោះវុធ! ទៅជុំគ្នានៅបណ្ណាល័យ!»

ខ្ញុំងាកក្រោយរកឡេង បន្ទប់ក្រោយខ្នងរបូតទ្វារបិទទៅវិញគ្រឹប។

ខ្ញុំឈរង៉េមង៉ាមមិនដឹងពន្យល់បែបម៉េចពេលពួកម៉ាកខ្ញុំនាំគ្នាមកដល់ ព្រោះបើសូម្បីតែខ្ញុំខ្លួនឯងក៏មិនទាន់យល់អ្វីជាអ្វីផង?

«ក្នុងបន្ទប់នេះមានអ្នកដួល!»

ខ្ញុំនិយាយបានតែប៉ុណ្ណោះព្រោះពួកម៉ាកខ្ញុំធ្វើមុខមាំងៗទាំងអស់គ្នា។

ពេលពួកគេចំហមាត់ស្តាប់ខ្ញុំនិយាយបន្ថែម៖

«មិញនេះសំឡេងមនុស្សស្រីហៅឱ្យជួយ!»

គេនាំគ្នាមើលទៅទ្វារដែលបិទជិតឈឹង។

ប្រហែលជា ទឹកមុខខ្ញុំច្បាស់លាស់ពេកបានជា បូរ៉ាដើរទៅរកទ្វារហើយលើកដៃគោះ។

ខ្ញុំអត់ដង្ហើមរង់ចាំការឆ្លើយតប ប៉ុន្តែគ្រប់យ៉ាងស្ងាត់សូន្យឈឹង។

សូម្បីតែសំឡេងថ្ងូរក៏មិនមានឮ។

«មានគេលេងខ្ញុំពិតហើយ! ចង់រកមុខឱ្យឃើញណាស់!»

ម្ដងនេះខ្មាសពួកម៉ាកផង ឆ្ងល់ផង ក្ដៅចិត្តផងខ្ញុំស្រែកទាំងខឹង។

ឃើញខ្ញុំខឹងហើយស្រែកឮៗបន្ទប់ជិតៗនោះបើកទ្វារចេញមកមើលព្រាតភ្លាមៗនោះ។

ជ្រុលទៅហើយ ខ្ញុំចង្អុលបន្ទប់នោះហើយតវ៉ា៖

«មកគោះទ្វារខ្ញុំពីរដងហើយ! គោះហើយ ពេលខ្ញុំបើកទ្វារមក រត់ចូលទៅវិញបាត់! មិញនេះលេងស្វិល ដេកឥដ្ឋហើយ ស្រែកឱ្យជួយទៀត!»

ពួកគេមើលខ្ញុំដោយក្រឡង់ៗ ចិត្តខ្ញុំរឹតតែអៀនក្ដៅមុខមាត់។

ខ្ញុំងាករកឡេងហើយនិយាយពន្យល់៖

«ខ្ញុំចង់សួរស្រីម្នាក់ហ្នឹងថា ចង់បានអី? លេងអ៊ីចឹងៗសមអត់?!»

ឡេងនៅភាំងៗមិនដឹងថាម៉េច ចំណែកបូរ៉ាងាកមើលទៅទ្វារបន្ទប់នោះភ្លឹះៗ ស្រាប់តែបងម្នាក់វ័យចាស់ជាងពួកខ្ញុំបន្តិច វែកហ្វូងមនុស្សដើរមក ហើយនិយាយមកកាន់ខ្ញុំ៖

«បន្ទប់នេះលែងមានគេនៅយូរហើយ!»

ខ្ញុំងាកមកវិញរហ័សដូចផ្លេកបន្ទោរ។

បងនោះងក់ក្បាលបញ្ជាក់ផ្ទួនពីលើសម្ដីគាត់ ធ្វើឱ្យខ្ញុំតវ៉ា៖

«អ្នកណាថា?!»

គ្រប់គ្នាជួយនិយាយាគាត់ភ្លាម៖

«ត្រូវហើយ បន្ទប់នេះ គេប្រាប់ថា លិចពិតាននៅអត់កើតទេ!»

ខ្ញុំងីងើរសម្លឹងបូរ៉ា ឡេងលូកមាត់ភ្លាម៖

«ត្រូវហើយវុធកាលខ្ញុំចូលដំបូងក៏ឮគ្រូប្រាប់អ៊ីចឹងដែរ!»

ខ្ញុំស្លុតហើយវិលមុខ។

សំឡេងមិត្តខ្ញុំម្នាក់ទៀតឈ្មោះទីន និយាយម្ដងបន្ទាប់ពីស្ងាត់យូរហើយ៖

«ចំណែកនិស្សិតស្រីវិញ អ្នកណាគេមកចេញចូលអាគារស្នាក់នៅប្រុសៗ! ខ្ញុំនៅទីនេះ១ឆ្នាំហើយ មិនដែលមានទេ!»

ខ្ញុំងាកទៅម្នាក់សុទ្ធតែសម្លឹងមកខ្ញុំដូចចម្លែក។

ខ្ញុំដឹងថាខ្ញុំទើបមកនៅជាង១០ថ្ងៃ គេមិនស្គាល់ខ្ញុំមិនអីទេតែគេគួរដឹងថាខ្ញុំមិនលេងកុហកបែបនេះបានអ្វីនោះដែរ។

ខ្ញុំខឹងណាស់ ងាកទៅរកទ្វារបន្ទប់នោះ ហើយដើរទៅជិត និយាយឮ៖

«លេងឱ្យសប្បាយណ៎ា គង់តែមានថ្ងៃទេ!»

ថាចប់ខ្ញុំបកចូលបន្ទប់ដេកវិញបិទទ្វារគ្រាំ។

ពួកគេបំបែកគ្នាយឺតៗទៅរកកន្លែងវិញតែរៀងខ្លួន នេះបើតាមស្មាន ព្រោះខ្ញុំផ្ទៀងស្តាប់ឮស្នូរជើងមនុស្សកាន់តែឆ្ងាយៗទៅ។

ពួកម៉ាកខ្ញុំវិញ នាំគ្នាចូលមកដល់ក្នុងកន្លែងសម្រាកដែរ តែអត់មានអ្នកណាហ៊ាននិយាយអ្វីទាំងអស់ព្រោះគេប្រហែលជាដឹងថាខ្ញុំកំពុងខឹង។

ពេលពីរនាក់ទៀតផ្លាស់ខោអាវហើយចេញទៅក្រៅអស់ បូរ៉ាមកអង្គុយក្បែរហើយនិយាយខ្សឹបៗដាក់ខ្ញុំ៖

«វុធឯងឃើញមែនអី?»

ខ្ញុំងក់ក្បាល។

គេនោះក៏ជជែកបន្ថែម៖

«តិចខ្មោចលង!»

ខ្ញុំចាប់ផ្តើមគិត តែមាត់តវ៉ា៖

«ខ្ញុំអ្វីៗច្បាស់នៅនឹងភ្នែក! អាណាម្នាក់វាពួននៅហ្នឹងវាលេងខ្ញុំ!»

បូរ៉ាសួរទៀត៖

«វុធឯងឃើញអីខ្លះ?»

«ទ្វារបើក ហើយបិទខ្លួនឯង! សំឡេងមនុស្សថ្ងូរឈឺចាប់ ហើយមនុស្សស្រីដេកនៅនឹងឥដ្ឋ!»

ប៉ូវ៉ានៅស្ងៀមងាកសម្លឹងទៅក្រៅបង្អួច។

គិតចុះគិតឡើង គេដើរចេញទៅហើយខ្ញុំឮស្នូរគោះទ្វារ។

«ខាងក្នុងមានអ្នកណានៅអត់?»

គឺប៉ូវ៉ាកំពុងស្វែងរកការពិតឱ្យខ្ញុំ។

គេគោះទ្វារបន្ទប់ចម្លែកនោះពេលដែលចិត្តខ្ញុំក៏កំពុងអន្ទះសារ។

គេគោះហើយហៅតិចៗច្រើនដងនៅតែគ្មានចម្លើយ

មានភាគបន្ត